ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

47/5

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៨០
ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ២០១៣
សាលដីកា
លេខ : ១៣៩ "ង"
ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤

# សាលដីកា

## នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៤។

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោក ជាចៅក្រម

ក្រឡាបញ្ជី

លោកស្រី [redacted]

តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

ដើមចោទៈអ្នកស្រី ម៉េង ហេងហួរ (ម្ចាស់បណ្តឹងសាទុក្ខ) អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរជាងសំណង់ មានទីលំនៅសព្វថ្ងៃផ្ទះលេខ០៨អឺ១ ផ្លូវលេខ ៥១៤ ក្រុមទី ១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

ចុងចម្លើយ: លោក[redacted] ណុប (ចុងបណ្តឹងសាទុក្ខ) អាយុ ៤៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ១៨៥ ផ្លូវលេខ ១០១៩ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ តំណាងដោយប្រពន្ធឈ្មោះ [redacted] សុខណារី

១៧០



Scanned with CamScanner

មេធាវី : លោក [redacted] តំណាងដោយអាណត្តិ

**<u>អំពីវិវាទ :</u>** ប្ដឹងទាមទារប្រាក់

## <u>អំពីអង្គហេតុ និង ចំណុចវិវាទ:</u>

**<u>ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>**

កាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឈ្មោះ [redacted] ហេងហួរ បានទទួលម៉ៅការសាងសង់ផ្ទះ ០២ល្វែង តម្លៃ ៣០.០០០ដុល្លា អោយទៅឈ្មោះ [redacted] ណុប និង ប្រពន្ធដោយបានធ្វើកិច្ចសន្យាត្រឹមត្រូវ ដោយនៅក្នុងកិច្ចសន្យាមានការបែងចែកជា ០៦ដំណាក់កាល ក្នុងមួយដំណាក់កាលឈ្មោះ [redacted] ណុប និង ប្រពន្ធត្រូវទូទាត់ប្រាក់អោយឈ្មោះ [redacted] ហេងហួរ ចំនួន ៥.០០០ដុល្លា នៅពេលកំពុងសាងសង់ឈ្មោះ [redacted] ណុប និង ប្រពន្ធទូទាត់ប្រាក់អោយឈ្មោះ [redacted] ហេងហួរ មិនទាន់គ្រប់ទេ នៅខ្វះចំនួន ១១.០៩៥ដុល្លា( មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក)ទៀត ពុំព្រមទូទាត់ ដោយឈ្មោះ [redacted] ណុប និង ប្រពន្ធចេះតែប្រកែកថា បានទូទាត់ឱ្យរួចរាល់អស់ហើយ តែធាតុពិតគាត់ពុំទាន់បានទូទាត់អោយនោះទេ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧៤"ធ"ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេច :**

១-អោយចុងចម្លើយឈ្មោះ [redacted] ណុប សងប្រាក់ទៅដើមចោទឈ្មោះ [redacted] ហេងហួរ :-

ក/ប្រាក់ដើមចំនួន ១១.០៩៥ដុល្លា( មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ។

ខ/សងការប្រាក់ចំនួន ៥%ក្នុងមួយឆ្នាំ លើទឹកប្រាក់ដើមចំនួន ១១.០៩៥ដុល្លា(មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) រហូតដល់ថ្ងៃសងគ្រប់ចំនួន។

គ/សងប្រាក់ខាតបង់ផ្សេងៗចំនួន ៥០០ដុល្លា( ប្រាំពាន់ដុល្លាអាមេរិក) ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

២-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

*សាលក្រមនេះ ត្រូវបានឈ្មោះ [redacted] ណុប ប្ដឹងឧទ្ធរណ៍តាមបណ្ដឹងលេខ ៦៦ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។*

**បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៦"ក្រIVអ"ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍សំរេច :**

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍លេខ ៦៦ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ណុប



Scanned with CamScanner

ត្រង់អោយសងប្រាក់ ១.០៨០ដុល្លាអាមេរិក។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៧៤"ធ" ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែត្រង់អោយចុងចម្លើយឈ្មោះ [redacted] ណុប សងប្រាក់ទៅដើមចោទចំនួន ១១.០៩៥ដុល្លាអាមេរិក ត្រូវកែប្រែទៅជាអោយសងចំនួន ១.០៨០ដុល្លាអាមេរិក និង សងការប្រាក់ ៥% លើប្រាក់ចំនួន ១.០៨០ដុល្លាអាមេរិកវិញ។ ចំណុចផ្សេងទៀតតម្កល់ទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកដើមចោទ។

៤-សាលដីកានេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល ១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះ ត្រូវបានឈ្មោះ [redacted] ហេងហួរ ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៥៧ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។*

**ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u>:**

**ឈ្មោះ [redacted] ហេងហួរ ធ្វើសេចក្តីថ្លែងការណ៍ថា :** ទឹកប្រាក់ចំនួន ១.០៨០ដុល្លា គឺជាប្រាក់ដែលចុងចម្លើយនៅខ្វះថ្លៃចាក់បួងសេ។ ចំពោះប្រាក់សាងសង់ចំនួន ៣០.០០០ដុល្លា ចុងចម្លើយបានបង់អោយខ្លួនបានតែ ២ម៉ឺនដុល្លាប៉ុណ្ណោះ ដូច្នេះចុងចម្លើយនៅខ្វះប្រាក់ថ្លៃសាងសង់ចំនួន ១ម៉ឺនដុល្លាទៀត ដូចមានលិខិតប្រគល់ប្រាក់ចំនួន ៤លើក ស្មើនឹងទឹកប្រាក់ ៥.០០០ដុល្លា គុណ ៤= ២០.០០០ដុល្លា ជូនក្រុមប្រឹក្សាពិនិត្យជាភស្តុតាង។

**ឈ្មោះ [redacted] សុខណារី ធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួននៅជំពាក់តែប្រាក់ចាក់បួងសេចំនួន ១.០៨០ ដុល្លាប៉ុណ្ណោះ ឯប្រាក់ថ្លៃសាងសង់ចំនួន ៣០.០០០ដុល្លា ខ្លួនបានបង់អោយដើមចោទគ្រប់ចំនួនហើយ គឺមាន ០៦ដំណាក់កាល ហើយ១ដំណាក់កាលមានទឹកប្រាក់ ៥.០០០ដុល្លា ប៉ុន្តែនៅដំណាក់កាលទី ៥ និង ៦ ដើម-ចោទ បានចុះនៅក្នុងសៀវភៅបើកប្រាក់ឈ្នួលអោយកម្មករគាត់ ដោយគាត់អះអាងថាមិនបានយកលិខិតប្រគល់ទទួលប្រាក់ជាប់មកជាមួយ។

**លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា :** ចុងចម្លើយនៅខ្វះប្រាក់ថ្លៃសាងសង់កូនក្តីខ្លួនចំនួន១១.០៩៥ដុល្លាទៀត ។ នៅសាលាដំបូងចុងចម្លើយពុំមានឯកសារជាលាយល័ក្ខអក្សរទេ ទើបតុលាការសំរេចតាមការប្តឹងទាមទាររបស់កូនក្តីខ្លួន ។ នៅសាលាឧទ្ធរណ៍ទើបចុង-ចម្លើយដាក់ឯកសារចំនួន ៤ច្បាប់ ហើយត្រូវសាលាឧទ្ធរណ៍សំរេចកែប្រែពីសងប្រាក់ចំនួន ១១.០៩៥ដុល្លាអា-មេរិក មកនៅត្រឹម ១.០៨០ដុល្លាអាមេរិកទៅវិញ។

១ៗ/២

Scanned with CamScanner

សំណូមពរ : សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា :ការដែលកូនក្តីខ្លួនមិនបានដាក់ឯកសារភស្តុតាងនៅសាលាដំបូងនេះ មកពីកូនក្តីខ្លួនមិនយល់ដឹងពីផ្លូវច្បាប់ ទើបមកដល់សាលាឧទ្ធរណ៍ ខ្លួនបានរៀបចំដាក់ភស្តុតាងដើម្បីការពារផលប្រយោជន៍ផ្លូវច្បាប់ជូនកូនក្តីខ្លួន ហើយសាលាឧទ្ធរណ៍ក៏បានទទួលស្គាល់ថាជាភស្តុតាងពិតប្រាកដមិនមែនក្លែងទេ ។ បើកូនក្តីខ្លួនមិនបានទូទាត់ថ្លៃសាងសង់ឱ្យគាត់ គឺគាត់ប្រាកដជាមិននៅធ្វើបន្តអោយកូនក្តីខ្លួនទេ ។ នៅដំណាក់កាលចាក់ប្លង់សេតម្លៃ ៦ពាន់ដុល្លា ក៏គាត់ទទួលស្គាល់ថា កូនក្តីខ្លួននៅខ្វះគាត់ចំនួន ១.០៨០ដុល្លា ។ នៅដំណាក់កាលពី ៥ និង ៦ ដើមចោទបានទទួលប្រាក់ចំនួន ១០.០០០ដុល្លាពីកូនក្តីខ្លួន ដោយបានចុះក្នុងសៀវភៅបើកប្រាក់អោយកម្មករ សុំអោយគាត់យកសៀវភៅនោះមកបង្ហាញតុលាការ ។

សំណូមពរ : សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ·

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និង សេចក្តីថ្លែងហេតុរបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៩៧ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ហេងហួរ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពសាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបង្គាប់អោយចុងចម្លើយឈ្មោះ [redacted] ណុប សងប្រាក់ទៅដើមចោទចំនួន ១.០៨០ដុល្លាអាមេរិក និង សងការប្រាក់ ៥% លើប្រាក់ជំពាក់ចំនួន ១.០៨០ដុល្លាអាមេរិកនោះមិនទាន់មានមូលដ្ឋានច្បាស់លាស់ទេ ពីព្រោះតុលាការសាលាឧទ្ធរណ៍មិនបានពិចារណាអំពីលិខិតនៃការសងទេ ។ តាមភស្តុតាងរបស់ដើមចោទបង្ហាញថា មានការសងមានបួនលើក លើកទី១ថ្ងៃទី ២០-០២-២០០៩ ចំនួន ៥.០០០ដុល្លាអាមេរិក, លើកទី២ ថ្ងៃទី ១១-០៣-២០០៩ ចំនួន ៥.០០០ដុល្លាអាមេរិក, លើកទី ៣ ថ្ងៃទី ២៥-០៣-២០០៩ ចំនួន៥.០០០ដុល្លាអាមេរិក, លើកទី ៤ ថ្ងៃទី ១២-០៤-២០០៩ ចំនួន ៥.០០០ដុល្លាអាមេរិក ។ ឯលិខិតភស្តុតាងរបស់ចុងចម្លើយបង្ហាញថា ការសងមានតែមួយលើកទេ គឺ ៥.០០០ដុល្លា នៅថ្ងៃទី ២០-០២-២០០៩ រីឯប្រាក់ចំនួន ១.០៨០ដុល្លាអាមេរិក គូភាគីបានឯកភាពថា ជាប្រាក់នៅជំពាក់ថ្លៃចាក់ប្លង់សេទេ ។



Scanned with CamScanner

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២៦ ក្រ IV "អ" ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះទាស់នឹងគតិច្បាប់ ។

ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលបណ្ដឹងសាទុក្ខលេខ ១៥៧ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៣ របស់ឈ្មោះ [redacted] ហេងហួរ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២៦ ក្រIV"អ" ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-ប្រាក់ប្រដាប់ក្ដីជាន់តុលាការកំពូលជាបន្ទុករបស់ភាគីចុងចម្លើយ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៤
ប្រធាន
[redacted]



Scanned with CamScanner